# ការអំពាវនាវឱ្យមានការចូលរួមចំណែកជាគំនិតស្តីពីមុខងារដែលនៅសេសសល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពាក់ព័ន្ធនឹងជនរងគ្រោះ

## សារណាពីអង្គការយុវសន្តិភាព

**ផ្ញើជូន ៖ ចៅក្រម យូ ឧត្តរា និងចៅក្រម Chaudia FENZ សហចៅក្រមរបាយការណ៍ស្តីពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ**

អង្គការយុវសន្តិភាព (YFP) មានសេចក្តីសោមនស្សរីករាយក្នុងការដាក់សំណើខាងក្រោមស្តីពីកិច្ចសន្ទនាអន្តរជំនាន់ដើម្បីឆ្លើយតបនឹងការអំពាវនាវរបស់ អ.វ.ត.ក ឱ្យមានការចូលរួមចំណែកជាគំនិតស្តីពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ។ ក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាលដ៏មានកិត្តិនាមមួយនៅកម្ពុជា អង្គការយុវសន្តិភាព បាន និងកំពុងធ្វើការងារដ៏សំខាន់ក្នុងការបង្កើតឱ្យមានសង្គមសន្តិភាព និងយុត្តិធម៌សង្គមក្នុងប្រទេសកម្ពុជា តាមរយៈការបណ្តុះបុគ្គលគំរូល្អ និងភាពជាពលរដ្ឋដ៏សកម្មក្នុងចំណោមយុវជនដែលយល់ និងអនុវត្តវប្បធម៌សន្តិភាព។ មុខងារនៅសេសសល់របស់ អ.វ.ត.ក ដែលពាក់ព័ន្ធនឹងជនរងគ្រោះ ដែលសម្របសម្រួលកិច្ចសន្ទនា ការយល់ដឹង និងការរៀនសូត្រក្នុងចំណោមមនុស្សជាច្រើនជំនាន់ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាកេរដំណែលរបស់ អ.វ.ត.ក ជួយពង្រឹងចំណេះដឹងស្តីពីខ្មែរក្រហម និងការទទួលខុសត្រូវពាក់ព័ន្ធ ក៏ដូចជាពង្រឹងការយល់ដឹង និងកិច្ចសន្ទនាក្នុងគ្រួសារ និងសហគមន៍នៅទូទាំងប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០០៧ មក អង្គការយុវសន្តិភាពបានចូលរួមក្នុងគម្រោងផ្សេងៗ ជំរុញលើកទឹកចិត្តឱ្យជនរងគ្រោះនៃរបបខ្មែរក្រហមចែករំលែករឿងរ៉ាវ និងដំណើររឿងរបស់ពួកគេ និងគម្រោងដែលពង្រឹងកិច្ចសន្ទនារវាងជនរងគ្រោះនៃរបបខ្មែរក្រហម និងយុវជននៅទូទាំងប្រទេសកម្ពុជា។

*ភាពពាក់ព័ន្ធនៃការចូលរួមជាមួយជនរងគ្រោះ និងយុវជន*

ក្នុងប្រទេសកម្ពុជា ចំណេះដឹងស្តីពីរបបខ្មែរក្រហម និងការទទួលខុសត្រូវដែល អ.វ.ត.ក កំពុងអនុវត្ត គឺនៅមានកម្រិតទាប។ កម្ពុជានៅតែជាប្រទេសមួយដែលមិនសូវមានកិច្ចសន្ទនាស្តីពីរបបនេះ ហើយការផ្តល់ព័ត៌មានក្នុងគ្រួសារ ផ្តល់ខ្លឹមសារ និងការពិតខុសៗគ្នា។

ការចូលរួមជាមួយជនរងគ្រោះ ក៏ដូចជាយុវជនផងដែរនោះនៅក្នុងសកម្មភាពនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ ដោយ អ.វ.ត.ក នឹងធានាបានថា ប្រជាជនកម្ពុជាភាគច្រើនបំផុតនឹងត្រូវបានដាក់បញ្ចូលក្នុងការងារ និងកេរដំណែលរបស់ អ.វ.ត.ក។ ការងារអន្តរជំនាន់ និងគម្រោងកិច្ចសន្ទនារបស់អង្គការយុវសន្តិភាព នឹងធានាថា ៖

- ជនរងគ្រោះ និងយុវជនបង្កើនការយល់ដឹងរបស់ពួកគេស្តីពីប្រវត្តិសាស្ត្រដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហម បុព្វហេតុនៃអំពើប្រល័យពូជសាសន៍ និងកិច្ចខិតខំប្រឹងប្រែងផ្សះផ្សារ
- យុវជនកម្ពុជាដែលបានកើតក្រោយសម័យខ្មែរក្រហម និងមានភាគរយច្រើនជាងគេក្នុងចំនួនប្រជាជនសរុប បានចូលរួមក្នុងការស្វែងរកយុត្តិធម៌ ការទទួលខុសត្រូវ និងការផ្សះផ្សារជាតិនៅកម្ពុជាតាមរបៀបដែលផ្អែកតាមព័ត៌មានត្រឹមត្រូវ និងសន្តិវិធី។
- មានការផ្តល់ចន្លោះសុវត្ថិភាពសម្រាប់ឱ្យប្រជាជនកម្ពុជាចែករំលែកបទពិសោធន៍ រវាងក្មេងជំនាន់ក្រោយ និងមនុស្សចាស់ក្នុងគ្រួសារ និងក្នុងសហគមន៍ ដែលលើកកម្ពស់ការផ្សះផ្សារ និងការយល់ដឹងពី អ.វ.ត.ក ក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅកម្ពុជា
- ការជំរុញឱ្យយុវជនដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការយុត្តិធម៌អន្តរកាល និងផ្សះផ្សារ ក្រោមការផ្តួចផ្តើមដោយ អ.វ.ត.ក។

*សំណើ*

ក្នុងការដាក់សំណើនេះ យើងទទួលស្គាល់ និងយល់ថា មុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ គួរស្ថិតក្នុងវិសាលភាពនៃអ្វីដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ អ.វ.ត.ក នឹងដើរតួនាទីជាអ្នកអនុវត្តផ្ទាល់នូវសកម្មភាពដែលស្នើឡើង។ សកម្មភាពដែលបានស្នើឡើងក្នុងសំណើនេះ អាចមានរយៈពេលអនុវត្តរហូតដល់ ៣ ឆ្នាំ។ សកម្មភាពទាំងនេះនឹងទទួលបានជំនួយមូលនិធិជាប់លាប់ និងផ្តោតសំខាន់លើផ្នែក និងក្រុមគោលដៅជាក់លាក់ដើម្បីឱ្យបន្សុីគ្នានឹងភាពចាំបាច់នៃមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ នៅ អ.វ.ត.ក។

សំណើនេះកើតចេញពីគម្រោងនានាដែលអង្គការយុវសន្តិភាពបានអនុវត្ត ហើយនឹងប្រើប្រាស់នាពេលអនាគត ដូចជា គម្រោងអ្នកជួយសង្គ្រោះ ដែលអង្គការយុវសន្តិភាពកំពុងអនុវត្តក្នុងឆ្នាំ២០២២។ គម្រោងអ្នកជួយសង្គ្រោះ គឺជាគម្រោងផ្សព្វផ្សាយដែលមានគោលបំណងរ៉ាយរ៉ាប់ពីរឿងរ៉ាវរបស់មនុស្សសាមញ្ញដែលក្លាយខ្លួនជា "អ្នកជួយសង្គ្រោះ" ក្នុងអំឡុងរបបខ្មែរក្រហម និងលើកកម្ពស់សារៈសំខាន់នៃការជំរុញភាពអង់អាចរបស់ប្រជាពលរដ្ឋប្រកបដោយក្រមសីលធម៌ក្នុងសង្គម (*ប៉ាន ក្លាហាន*)។ "គម្រោងអ្នកជួយសង្គ្រោះ" នឹងរួមចំណែកយ៉ាងច្រើនដល់ដំណើរការនេះ តាមរយៈការចែករំលែករឿងរ៉ាវរបស់អ្នកជួយសង្គ្រោះ ការផ្តល់គំរូវិជ្ជមាននៃឥរិយាបថជួយសង្គ្រោះ និងការលើកទឹកចិត្តឱ្យក្លាហានប្រកបដោយក្រមសីលធម៌ ក៏ដូចជាអប់រំយុវជនឱ្យក្លាយជាភ្នាក់ងារនៃកិច្ចសន្ទនា និងការផ្លាស់ប្តូរក្នុងប្រទេសកម្ពុជា។ ការសម្ភាសន៍ និងការប្រមូលការរ៉ាយរ៉ាប់ដំណើររឿងទាំងនេះ ធ្វើឡើងដោយយុវជនដែលត្រូវបានបណ្តុះបណ្តាលដោយអង្គការយុវសន្តិភាព និងបានបង្កើតទំនាក់ទំនង និងទំនុកចិត្តជាមួយជនរងគ្រោះ ដើម្បីជំរុញបរិយាកាសអំណោយផលសម្រាប់កិច្ចសន្ទនា និងការផ្លោះប្តូរយោបល់ទាំងនេះ។ ក្រុមគោលដៅនៃសំណើនេះ គឺយុវជនកម្ពុជា អតីតអ្នកជួយសង្គ្រោះ និងជនរងគ្រោះនៃរបបខ្មែរក្រហម ក៏ដូចជាពលរដ្ឋខ្មែរទូទៅ។ ក្នុងរយៈពេល ៣ ឆ្នាំ ខាងមុខ អង្គការយុវសន្តិភាពនឹងបន្តជួយអភិរក្សទីតាំងឧក្រិដ្ឋកម្ម។ អ.វ.ត.ក គួរផ្តោតការយកចិត្តទុកដាក់លើទីតាំងឧក្រិដ្ឋកម្មចាប់ពីពេលបច្ចុប្បន្នរហូតដល់ទីបំផុត។

កេរដំណែលរបស់ អ.វ.ត.ក ផ្សារភ្ជាប់នឹងកិច្ចសន្ទនាដែលលេចចេញពីការចូលរួមរបស់ជនរងគ្រោះ និងកម្មវិធីផ្សព្វផ្សាយរបស់ អ.វ.ត.ក ផ្ទាល់។ គោលដៅដ៏សំខាន់មួយរបស់ អ.វ.ត.ក គឺការខិតខំផ្តល់ព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបានស្តីពីសកម្មភាពរបស់តុលាការ និងអប់រំសាធារណជន តាមរយៈការធ្វើការប្រកបដោយតម្លាភាពក្នុងការកសាងទំនុកចិត្តរបស់សាធារណជនក្នុងដំណើរការតុលាការ។ ចំណុចនេះរួមមានការកំណត់យកយុវជនជាក្រុមគោលដៅសម្រាប់សកម្មភាពផ្សព្វផ្សាយ និងអប់រំ។ ខណៈដែលការបង្កើតការពិត និងការទទួលខុសត្រូវចំពោះរបបខ្មែរក្រហម នៅតែមានសារៈសំខាន់សម្រាប់ការស្តារឡើងវិញពីអតីតកាល និងការសម្រេចបានការផ្សះផ្សារ សំណើនេះអាចរួមចំណែកជាវិជ្ជមានដល់ការកសាងអនាគតរបស់ កម្ពុជា តាមរយៈការដើរតួនាទីជាសរសស្តម្ភវិជ្ជមានមួយដែលផ្តោតសំខាន់លើរឿងរ៉ាវរបស់ជនរងគ្រោះ និងការពង្រឹងក្តីមេត្តាករុណាក្នុងសង្គម ជាពិសេសក្នុងចំណោមមនុស្សជំនាន់ក្រោយ។ មុខងារដែលនៅសេសល់ពាក់ព័ន្ធនឹងជនរងគ្រោះ នឹងជះឥទ្ធិពលលើកេរដំណែលរបស់តុលាការនេះ ហើយក្នុងការបំពេញការងារនេះ ចាំបាច់ត្រូវមានការវិនិយោគលើមនុស្សជំនាន់ក្រោយ។ គម្រោងដែលផ្តោតលើកិច្ចសន្ទនាអន្តរជំនាន់ ជាវិធីដ៏ជាក់លាក់មួយ

សម្រាប់ការសម្របសម្រួលកេរដំណែលនេះ ក៏ដូចជាផ្តល់លទ្ធភាពឱ្យជនរងគ្រោះ និងអ្នករស់រានមានជីវិត ចែករំលែកដំណើររឿងរបស់ពួកគេ និងព្យាបាលរបួសស្នាមក្នុងដំណើរការនេះ។

យើងខ្ញុំស្វាគមន៍ការផ្តល់ឱកាសសម្រាប់ការបញ្ជាក់ពីសារណារបស់យើង និងទន្ទឹងរង់ចាំការចូលរួមក្នុងកិច្ចសន្ទនាជាបន្តបន្ទាប់ជាមួយ អ.វ.ត.ក ស្តីពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ។ យើងខ្ញុំសូមអរគុណដល់ អ.វ.ត.ក និងចៅក្រម យូ ឧត្តរា និងចៅក្រម Fenz ចំពោះការផ្តល់ឱកាសឱ្យមានការដាក់សំណើនេះ និងការប្តេជ្ញាចិត្តរបស់ពួកគាត់ចំពោះជនរងគ្រោះ។

ម៉ន សុខឿន<br>
នាយកប្រតិបត្តិអង្គការយុវសន្តិភាព<br>
*និង*<br>
Sangeetha Yogendran<br>
ទីប្រឹក្សាអង្គការយុវសន្តិភាព និងអ្នកស្រាវជ្រាវ (សាកលវិទ្យាល័យ Ghent)